# «ខ្ញុំ» និង «អញ» (ភាគ២)

នៅក្នុងអត្ថបទភាគ១[១] ស្ដីពីពាក្យ «ខ្ញុំ» និង «អញ» យើងបានបង្ហាញអំពីពាក្យ «ខ្ញុំ» រួចមកហើយថា នៅសម័យមុនអង្គរនិងអង្គរ ពុំឃើញមានប្រើពាក្យនេះជាសព្វនាមបុរិសៈ បុរសទី១ឡើយ។ លុះមកដល់សម័យកណ្ដាលអំឡុងសតវត្សទី១៧-១៨ ទើបយើងឃើញពាក្យនេះប្រើខ្លះក្នុងដើមដដែល និងខ្លះប្រើជាសព្វនាមបុរិសៈ បុរសទី១។ ដូច្នេះ យើងនឹងបង្ហាញថាតើពីសម័យបុរាណ ពោលគឺសម័យមុនអង្គរនិងអង្គរ ខ្មែរយើងប្រើប្រាស់ពាក្យអ្វីសម្រាប់ហៅខ្លួនឯង?

ផ្អែកតាមភស្តុតាងភាសាខ្មែរតាមរយៈសិលាចារឹក បានបង្ហាញថា នៅសម័យបុរាណខ្មែរប្រើពាក្យ «អញ» សម្រាប់ហៅខ្លួនឯង។ នៅសម័យមុនអង្គរ ពាក្យនេះមានសំណេរជា «អញ៑» និង «អញ្ញ» ដែលសំណេរ «អញ៑» លេចឡើងច្រើនជាងគេ។ មកដល់សម័យអង្គរ ពាក្យនេះ នៅតែរក្សារូបរាងសំណេរ ដូចសម័យមុនអង្គរដដែល និងមានសំណេរមួយទៀតគឺ «អញ» ដែលចាប់ផ្ដើមមាននៅពេលដែលសញ្ញាវិរាម «៑» លែងប្រើប្រាស់ជាទៀងទាត់ដូចមុន[២]។ សំណេរ «អញ» នេះបន្តប្រើរហូតមកដល់សម័យកណ្ដាល និងពេលបច្ចុប្បន្នផងដែរ។ បើយើងពិនិត្យមើលលើបម្រែបម្រួលសំណេរស្រៈ «អ» ពីបុរាណមកជាសំណេរស្រៈ «អា» និង «អ់» នាពេលក្រោយៗមក យើងក៏ឃើញថាសំណេរពាក្យ «អញ» មានសរសេរទៅជា «អាញ» និង «អាញ់» ឬជា «អ័ញ» ផងក៏មាន។ យ៉ាងណាក្ដី នៅពេលមានវចនានុក្រម ក្រុមជំនុំសម្រេចយកសំណេរ «អញ» ជាអក្ខរាវិរុទ្ធ ហើយកំណត់ឱ្យអានថា [អាញ់] និងចាត់ទុកជាអញ្ញត្រសព្ទ។[៣]

---

[១] សូមអាន៖ https://ams.com.kh/khmercivilization/detail/18377

[២] សញ្ញាវិរាម «៑» គឺជាសញ្ញាដាក់នៅលើព្យញ្ជនៈ បង្ហាញថាព្យញ្ជនៈនោះជាព្យញ្ជនៈសុទ្ធ។ ព្យញ្ជនៈសុទ្ធជាព្យញ្ជនៈដែលគ្មានស្រៈអាស្រ័យជាមួយ។

[៣] សូមអាន៖ វចនានុក្រមខ្មែរ (ភាគ២) ១៩៦៨: ១១៩៨។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

ពាក្យ «អញ» នេះ ប្រើសម្រាប់មនុស្សទូទៅ គ្រប់វ័យ គ្រប់ឋានៈតួនាទី នៅក្នុងសង្គមខ្មែរបុរាណ។ ជាក់ស្តែង ដូចនៅក្នុងសិលាចារឹកប្រាសាទក្តីតាគម K.២៤៥ ម្ចាស់សិលាចារឹកដែលមិនបានបញ្ចេញឈ្មោះ បានឱ្យហៅខ្លួនរបស់គាត់ថា «អញ» ដូចមាននៅក្នុងឃ្លា៖ «...អញ៑អញ្ចេញ៑កំម្រតេង៑អញ៑វ្រះគុរុស្ថាបនា អញ៑ឱយ៑តម្ប្រអេរុះទក្សិណានេះវ្រះនេះផោង៑ ត៑អញ៑ឱយ៑តកូន៑អញ៑...» (K.២៤៥៖ បន្ទាត់២១-២៣) ដែលអាចសម្រួលជាភាសាខ្មែរទំនើបបានថា «...អញអញ្ជើញកម្តែងអញព្រះគ្រូស្ថាបនា អញឱ្យដំរី សេះ ជាតង្វាយទក្ខិណា(សម្រាប់ការស្ថាបនា)ព្រះនៅទីនេះ ដែលអញឱ្យដល់កូនអញ...»។

អ្វីដែលកាន់តែបង្ហាញឱ្យឃើញកាន់តែច្បាស់អំពីការប្រើពាក្យ «អញ» នាសម័យបុរាណ ចំពោះមនុស្សទូទៅ គ្រប់ឋានៈនោះ យើងអាចពិនិត្យទៅលើសិលាចារឹកតាកឹងស្ថិតនៅក្នុងអតីតរាជធានីសម្ភុបូរ បច្ចុប្បន្នស្ថិតនៅស្រុកសំបូរ[៤] ខេត្តក្រចេះ។ សិលាចារឹកនេះចារនៅឆ្នាំ១០០១ បង្ហាញពីមន្ត្រីម្នាក់ឈ្មោះ «ទីយ៌ហោរ» មានឋានន្តរនាមជា «វាប» ជាអ្នកប្រចាំការនៅប្រាសាទដែលបានរកឃើញសិលាចារឹកនេះ បានសរសេរសំបុត្រទូលថ្វាយទៅព្រះមហាក្សត្រ ដោយរៀបរាប់ពីដំណើរដើមទងនៃការកកើតប្រាសាទនេះ និងពូជពង្សវង្សសន្តានគាត់ដែលនៅប្រចាំការនាប្រាសាទនេះពីដើមរហូតមក ក្នុងបំណងស្នើសុំបន្តជាអ្នកប្រចាំការនៅប្រាសាទនោះតទៅទៀត។ នៅក្នុងសេចក្តីសំបុត្រនោះ គាត់បានប្រើពាក្យហៅខ្លួនឯងថា «អញខ្ញុំ» ចំពោះព្រះមហាក្សត្រ។ ខាងក្រោមនេះជាសម្រង់ឃ្លាដកស្រង់ពីសិលាចារឹកនោះ៖

១- ៩២៣គកន្ទុវាប៑ទីយ៌ហោរឱយ៑សំន្វត៑គ៑វ្រះអាលក្សនមនិករុនាគ៑ត្រា

២- តប្រគស្តនាវ្រះកំម្រតេង៑អញ៑ចន្ទិយ ০ នេះគ៑ពោះហសំន្វត៑ ০ អញ៑ខ្ញុំបំចប់ទីយ៌

៣- ហោរ៑កំម្រតេង៑ជគត៑គំម្ពុបុរឱយ៑សំន្វត៑បិបង្គំថ្ប្វង៑និវេទនតធូលិវ្រះបាទធូ

៤- លិជេង៑វ្រះកំម្រតេង៑អញ៑តបរមបពិត្រនុក្ខ្វតជ្វកក្តិយ ০ [...]

---

[៤] ពាក្យ «សំបូរ» ជាឈ្មោះស្រុកនេះ ក្លាយមកពីឈ្មោះបុរាណថា «សម្ភុបុរ»។ ពាក្យ «សម្ភុ» អានត្រឹមជា [សំ] ចំណែកព្យាង្គ «ភុ» ខាងចុង ពុំអានទេ ដូចករណីពាក្យ «ភស្ម» ជាដើម។ ចំណែកឯពាក្យ «បុរ» ក្លាយមកជា «បូរ»។ បើចង់សរសេរដោយរក្សាជាតិសព្ទ ស្រុកនេះ គួរសរសេរជា «សម្ភុបូរ»។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

សេចក្ដីដកស្រង់ខាងលើនេះ អាចប្រែសម្រួលបានថា «មហាសករាជឆ្នាំ៩២៣ នូវវាបទីយ៍ហោរថ្វាយសំនូត្រ(សំបុត្រ)តាមរយៈព្រះអាលក្សណ៍។ មានព្រះករុណា(ត្រាស់ឱ្យ)ចារលើសិលាចារឹកនា(ប្រាសាទ)ព្រះគម្តែងអញចន្ទី។ នេះគឺសេចក្ដីសំនូត្រ(សំបុត្រ)៖ អញខ្ញុំ(ជា)អ្នកប្រចាំការ(នា)គម្តែងជគតសម្ភុបូរ (សូមក្រាប)ថ្វាយសំនូត្រ(សំបុត្រ)ដើម្បីក្រាបបង្គំទូលថ្វាយចំពោះធូលីព្រះបាទធូលីជើងព្រះគម្តែងអញដ៏បរមបពិត្រនូវកតញ្ញូភក្តី»។

ហេតុអ្វីត្រូវប្រើពាក្យ «អញខ្ញុំ» នេះ? បើមើលតាមសិលាចារឹក នៅសម័យមុនអង្គរយើងមិនទាន់ជួបប្រទះពាក្យនេះនៅឡើយទេ យើងឃើញពាក្យនេះតែក្នុងសម័យអង្គរបន្តរហូតមកដល់សម័យទំនើប និងប្រើចំពោះតែព្រះមហាក្សត្រ អាទិទេព ទេពតា និងព្រះតែប៉ុណ្ណោះ ដ្បិតបើយើងសម្រាយពាក្យនេះ មានន័យជាពាក្យទំនើបថា «ខ្ញុំជាអ្នកបម្រើ» ពោលគឺជាខ្ញុំបម្រើរបស់ព្រះមហាក្សត្រ ទេពតាជាដើម។ វចនានុក្រមខ្មែរ ក៏បានបង្ហាញថាមានពាក្យ «អញខ្ញុំ, អញខ្ញុំព្រះអង្គ, អញខ្ញុំម្ចាស់» ដែលមានន័យថា «ខ្ញុំ, ខ្ញុំព្រះអង្គ, ខ្ញុំម្ចាស់»[៩]។ នេះបញ្ជាក់ឱ្យឃើញថា ពាក្យ «អញ» គឺប្រើទូទៅមិនចំពោះ គឺប្រើបានជាមួយមនុស្សគ្រប់ឋានៈតូចធំ ទេពតា ព្រះជាដើម។ ចំណែកឯពាក្យ «ខ្ញុំ» ដាក់មកខាងក្រោយនោះ គឺប្រើក្នុងន័យលំអុតលំឱន ចំពោះអ្នកមានឋានៈខ្ពង់ខ្ពស់ ដោយបញ្ជាក់ថាខ្លួនជាអ្នកបម្រើរបស់អ្នកនោះ។ ដោយការប្រើកន្សោមពាក្យ «អញខ្ញុំ» សម្រាប់ហៅខ្លួនឯងចំពោះម្ចាស់ខ្លួនមានព្រះមហាក្សត្រ អាទិទេពជាដើម និងប្រើពាក្យ «ខ្ញុំម្ចាស់, ខ្ញុំព្រះអង្គ...» ជាដើមផង នាំឱ្យមានការប្រើខ្ញីមកត្រឹមជា «ខ្ញុំ» ទៅវិញ។

ពាក្យ «អញ» នេះ ជាធាតុមួយដែលចូលរួមបង្កើតឋានន្តរនាម តាំងពីសម័យមុនអង្គររហូតមក។ ឋានន្តរនាមនោះ រមែងជាប់ន័យទាក់ទងនឹងបុរសទី១ ដូចជាពាក្យ «កម្រតាង៑អញ៑ > កម្រតេង៑អញ៑ > កម្រតែងអញ > គម្តែងអញ» មានន័យថា «អម្ចាស់ខ្ញុំ លោកជាម្ចាស់នៃខ្ញុំ...»។ ខាងក្រោមនេះ គឺជាសម្រង់ឋានន្តរនាម ឬពាក្យសម្រាប់សម្គាល់ឋានៈនៅសម័យបុរាណ តាមរយៈសិលាចារឹកភាសាខ្មែរ៖

---

[៩] សូមអាន៖ វចនានុក្រមខ្មែរ (ភាគ២) ១៩៦៨: ១១៩៨។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

| សម័យមុនអង្គរ | សម័យអង្គរ | អត្ថន័យ |
|---|---|---|
| បុអញ | | អម្ចាស់ខ្ញុំ<br>គោរម្យងាររបស់ព្រាហ្មណ៍ជាន់ខ្ពស់ |
| បុចះអញ<br>បោចសិអញ | | |
| បុ/បូយាងអញ | | |
| តាងអញ | | គោរម្យងារនៃមន្ត្រីនៅបរមរាជវាំង ឬនៅតាមខេត្តធំៗ ផ្សេងៗ។ |
| | ស្តេងអញ | គោរម្យងាររបស់ព្រាហ្មណ៍ បុរោហិត រាជគ្រូ អ្នកអង្គម្ចាស់ រាជវង្សានុវង្ស។ |
| | កំស្តេងអញ | គោរម្យងារសម្រាប់អ្នកស្ថិតនៅក្នុងវណ្ណៈ អភិជន មន្ត្រីជាន់ខ្ពស់ មហាមន្ត្រី មហាសេនាបតី អ្នកអង្គម្ចាស់ ព្រាហ្មណ៍ជាន់ខ្ពស់។ |
| កំម្រតាងអញ | កំម្រតេងអញ | គោរម្យងារសម្គាល់ឋានៈខ្ពង់ខ្ពស់ច្រើនប្រភេទចាប់ពីព្រាហ្មណ៍ ព្រះសង្ឃ ម្ចាស់ក្សត្រី រាជវង្សានុវង្ស មេទ័ព ព្រះមហាក្សត្រ អាទិទេពជាដើម។ |

តាមរយៈការបង្ហាញមកនេះ យើងឃើញថាភាសារមែងមានការប្រែប្រួលជានិច្ច និងខុសប្លែកគ្នាទៅតាមសម័យកាល តំបន់ ក្រុមមនុស្សៗល។ ពាក្យបច្ចុប្បន្នដែលប្រែប្រួលមកពីពាក្យបុរាណណាមួយ ពុំសុទ្ធតែនៅរក្សាន័យដើមដដែលនោះទេ។ ពាក្យពីសម័យបុរាណ ក៏ពុំសុទ្ធតែអាចយកមកប្រើប្រាស់នៅក្នុងសម័យបច្ចុប្បន្ននោះដែរ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីឯកសារយោង

ហ៊ុន ឈុនតេង

២០២២. «ខ្ញុំ» និង «អញ» (ភាគ១). https://ams.com.kh/khmercivilization/detail/18377

ឡុង សៀម

២០០០. វចននានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី ៦-៨). ពេជ ពុម្ពភ្នំពេញ។

វចនានុក្រមខ្មែរ

១៩៦៨. វចនានុក្រមខ្មែរ ភាគ២. វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

## បញ្ជីរូបភាព



សិលាចារឹកសម័យមុនអង្គរ K.១០១០



សិលាចារឹកប្រាសាទព្រះគោ K.៣១៤




អត្ថបទដោយៈ ហ៊ុន ឈុនតេង